# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា អំពីអាជ្ញាធរខ្មែរនៅប្រទេសកម្ពុជា រំលោភលើសិទ្ធិប្រជាពលរដ្ឋរបស់ខ្លួន

**Website: www.hoksavann.org**

ថ្ងៃទី១៣ កញ្ញា ២០០៤

១-<u>បញ្ហារំលោភសិទ្ធិធ្វើបាតុកម្ម</u> ៖

តាមដំណឹងជាបន្តបន្ទាប់ពីទីក្រុងភ្នំពេញប្រទេសកម្ពុជាថា អាជ្ញាធរក្រុងភ្នំពេញ នៅតែប្រព្រឹត្តអំពើហឹង្សាអមនុស្សធម៌ មកលើប្រជាពលរដ្ឋរបស់ខ្លួន ។ នៅពេលថ្មីៗនេះ មានដំណឹងមួយគួរឲ្យអស់សំណើច អាជ្ញាធរក្រុងភ្នំពេញបានបញ្ជាឲ្យប៉ូលិសនិងកងអាវុធហត្ថ មានគ្នារាប់រយនាក់ទៅបង្ក្រាបចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យនិងក្រុមដទៃទៀតដែលមានគ្នាមិនដល់១០នាក់ផង ហើយជិះក្នុងស៊ីក្លូទៀត ដោយគ្មានអ្វីទាំងអស់ក្នុងដៃ ដើម្បីទាមទារឲ្យរដ្ឋាភិបាលបញ្ចុះតម្លៃប្រេងសាំង ។ ប៉ូលិសនិងកងអាវុធហត្ថ ដែលធ្វើការបំរើដាច់ថ្លៃរបស់អាជ្ញាធរក្រុងគ្មានការពិចារណា បានបញ្ចេញសាច់ដុំ បានសំឡុតគំរាមកំហែង អូសទាញក្រុមនិស្សិតឲ្យឡើងឡាន ទៅសួរចម្លើយនៅទីចាត់ការ ។ គួរឆ្ងល់ថា អ្នកបញ្ជាព្រមទាំងប៉ូលិសនិងកងអាវុធហត្ថទាំងនោះទៅបង្ក្រាបអ្វី ? បើនិស្សិតទាំងនោះជិះស៊ីក្លូដូចមនុស្សធ្វើដំណើរធម្មតាសោះ ឬមកអំពីអត់ការធ្វើ ឬក៏មកអំពីគ្មានការយល់ដឹងអំពីមុខនាទីរបស់ខ្លួន ព្រោះបើរង់ចាំឲ្យមានការប្រើអំពើហឹង្សា ទើបទៅបង្ក្រាបវាយូរពេក ឬក៏ទទួលបញ្ជាពីថ្នាក់លើថា ប្រជាពលរដ្ឋណាក៏ដោយឲ្យតែកំរើកមាត់ កំរើកដៃ កំរើកជើងប្រឆាំងរដ្ឋាភិបាល ប្រឆាំងបែបណាក៏ដោយ ត្រូវតែបង្ក្រាបជាដាច់ខាតកុំឲ្យកំរើកមាត់កំរើកដៃកំរើកជើងរួច ។

អាជ្ញាធរក្រុងភ្នំពេញពុំអនុញ្ញាតឲ្យប្រជាពលរដ្ឋធ្វើបាតុកម្មនិងកូដកម្មស្របតាមរដ្ឋធម្មនុញ្ញនេះ ដោយសំអាងមូលហេតុថា ការធ្វើបាតុកម្មកូដកម្មនេះ ពុំមែនជាដំណោះស្រាយទេ ហើយនាំឲ្យបង្កអសន្តិសុខ ។ ការបំបិទសិទ្ធិប្រជាពលរដ្ឋដោយសំអាងមូលហេតុនេះពុំសមហេតុផលទេ ព្រោះពិតជាគ្មានជនណាម្នាក់ចង់ធ្វើបាតុកម្មនិងកូដកម្មនេះទេបើគ្មានបញ្ហាគាបសង្កត់ប្រជាពលរដ្ឋ គ្មានការរំលោភសិទ្ធិប្រជាពលរដ្ឋ ឬគ្មានធ្វើឲ្យខូចប្រយោជន៍ប្រជាពលរដ្ឋទេ ។ មួយទៀត បើមានបញ្ហារំលោភនេះហើយ រដ្ឋាភិបាលបានព្យាយាមដោះស្រាយ នោះការធ្វើបាតុកម្មពុំកើតឡើងឡើយ ។ ដូចនេះ, បាតុកម្មនិងកូដកម្មនេះកើតឡើង ដោយសាររដ្ឋាភិបាលពុំយកចិត្តទុកដាក់ដោះស្រាយបំរើផលប្រយោជន៍ប្រជាពលរដ្ឋ ផ្ទុយទៅវិញ ទៅបំរើផលប្រយោជន៍ក្រុមហ៊ុនទុច្ចរិត អ្នកមានអំណាចទុច្ចរិតទៅវិញ បានជាបំបិទមាត់ប្រជាពលរដ្ឋបែបនេះ ។ មានសេចក្តីសង្ស័យថា អាចមានក្រុមហ៊ុនខ្លះ មានការចូលហ៊ុនជាមួយមន្ត្រីខ្មែរណាម្នាក់ ឬជាមួយបងប្អូនកូនចៅរបស់មន្ត្រីនោះ ដូចជាក្រុមហ៊ុនប្រេងសាំងដែលកំពុងមានបញ្ហាតម្លៃនេះ អាជ្ញាធរពាក់ព័ន្ធជួយការពារដោយខ្ទប់មាត់ប្រជាពលរដ្ឋមិនឲ្យតវ៉ា ។ ចំណែកមូលហេតុដែលសាលាក្រុងសំអាងថា ការធ្វើបាតុកម្មឬកូដកម្មមានដៃទទេ គ្មានកាំបិតគ្មានពូថៅគ្មានដំបងគ្មានអាវុធទេ តើបានអ្វីបង្កអសន្តិសុខ ? ផ្ទុយទៅវិញអ្នកដែលបង្កអសន្តិសុខ គឺប៉ូលិសនិងកងអាវុធហត្ថ ដែលធ្វើតាមបញ្ជាជនណាម្នាក់ថ្នាក់លើវិញទេ ដែលបង្កអសន្តិសុខដែលបង្ក្រាបដោយកាំភ្លើងនិងដំបងឆក់ ។ ដូច្នេះបើការបង្ក្រាបនោះប៉ះពាល់ដល់រាងកាយប្រជាពលរដ្ឋ ធ្វើឲ្យបាត់បង់ទ្រព្យសម្បត្តិ ឬធ្វើឲ្យខូចផ្លូវចិត្តប្រជាពលរដ្ឋ អាជ្ញាធរបង្ក្រាបនោះត្រូវទទួលខុសត្រូវនៅចំពោះមុខតុលាការ ព្រោះថាជនណាក៏ដោយ ទោះបីមានឋានៈខ្ពស់យ៉ាងណាក៏ដោយ បើមានការរំលោភលើសិទ្ធិប្រជាពលរដ្ឋ រំលោភច្បាប់ហើយ ត្រូវតែឡើងតុលាការកាត់ទោសតាមច្បាប់ នេះជារបបប្រជាធិបតេយ្យ ដែលផ្ទុយពីរបបកុម្មុយនិស្តនិយម ឬរបបផ្តាច់ការ ។ គួរឲ្យឆ្ងល់ថា តាំងពីសាលាក្រុងភ្នំពេញប្រើលទ្ធិផ្តាច់ការ រំលោភច្បាប់ រំលោភរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ដោយបំបិទស្ទើរតែទាំងស្រុង មិនអនុញ្ញាតឲ្យប្រជាពលរដ្ឋបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មឬកូដកម្មនេះ តំណាងរាស្ត្រខ្មែរនៅក្នុងរដ្ឋសភា ពុំដែលធ្វើអន្តរាគមន៍កោះហៅអភិបាលក្រុងភ្នំពេញ មកដេញដោលសាកសួរ អំពីការរំលោភរដ្ឋធម្មនុញ្ញ រំលោភសិទ្ធិប្រជាពលរដ្ឋរបស់អាជ្ញាធរក្រុង ដែលជាស្ថាប័ននីតិប្រតិបត្តិនេះ ។ តើសភាដែលប្រជាពលរដ្ឋបោះឆ្នោតឲ្យនេះ មានមុខងារធ្វើអ្វីខ្លះ ? បើពុំបំរើផលប្រយោជន៍ប្រជាពលរដ្ឋទេ មានតែរង់ចាំតែហៃអើជាមួយរដ្ឋាភិបាលប៉ុណ្ណោះ ។ បញ្ហានេះធ្ងន់ណាស់ បើនៅតែទុកឲ្យអាជ្ញាធរក្រុងប្រព្រឹត្តអំពើនេះតទៅទៀត បញ្ហាអយុត្តិធម៌ក្នុងសង្គម បញ្ហាជិះជាន់គ្នា បញ្ហាពុករលួយ បញ្ហាភាពក្រីក្រ ពុំអាចមានផ្លូវចេញរួចឡើយ ដោយសារតែបិទមិនឲ្យប្រជាពលរដ្ឋចូលរួមបញ្ចេញមតិជាមួយរដ្ឋាភិបាល ក្នុងការការពារជាតិនិងកសាងជាតិនេះ ។

២- <u>បញ្ហាបំផ្លាញផ្ទះប្រជាពលរដ្ឋ</u> ៖

ប្រជាពលរដ្ឋខ្មែរនៅខណ្ឌឫស្សីកែវរាជធានីភ្នំពេញជាង២០០គ្រួសារបានត្រូវកងកម្លាំងសន្តិសុខ បផ្តិចបំផ្លាញផ្ទះសំបែងរបស់ពួកលោកខ្ទេចខ្ទីអស់ ដោយអនុវត្តតាមសាលក្រមរបស់តុលាការ ។ ពីដើមគេនិយាយថា ហឹង្សាតែងមាននៅក្នុងចំណោមប្រជាពលរដ្ឋ ឥឡូវនេះអំពើហឹង្សាកើតចេញពីអាជ្ញាធរកាន់អំណាចតែម្តង ។ ប្រជាពលរដ្ឋតែងតែក្តីចាញ់អ្នកកាន់អំណាច និងអ្នកមានប្រាក់កាស ។ ម្យ៉ាងទៀត គេដឹងទូទៅថា តុលាការខ្មែរពុករលួយស៊ីសំណូកពុំឯករាជ្យ នៅក្រោមឥទ្ធិពលអ្នកកាន់អំណាច ។ អំពើហឹង្សានេះបានធ្វើឲ្យប្រជាពលរដ្ឋគ្មានជំរក ដេកនៅដីដោយសម្ភារៈប្រើប្រាស់បានត្រូវត្រាក់ទ័រឈ្នូសបំផ្លាញ ស្ត្រីខ្លះផ្ទៃពោះ ស្ត្រីខ្លះមានកូនខ្ចី បានទទួលនូវការឈឺចាប់យ៉ាងខ្លាំងក្លាបំផុត ។ បញ្ហាថា តើការកាត់សេចក្តីឲ្យប្រជាពលរដ្ឋចាញ់ រហូតចេញសាលក្រមឲ្យកំទេចផ្ទះរបស់ប្រជាពលរដ្ឋនោះមានយុត្តិធម៌ឬទេ ? ទោះប្រជាពលរដ្ឋអះអាងថា ពួកលោកធ្លាប់រស់នៅទីនេះជាយូរមកហើយ នេះជារឿងមួយ រឿងមួយទៀត ចុះបើអនុវត្តតាមសាលក្រមនោះទៅ តើឲ្យប្រជាពលរដ្ឋរស់នៅទីណា ? ដូច្នេះការអនុវត្តន៍តាមសាលក្រមនេះ ទុកជាការសម្លាប់ប្រជាពលរដ្ឋដោយចេតនា ព្រោះពុំបានដោះស្រាយបន្លាស់ឲ្យប្រជាពលរដ្ឋរស់នៅទីណា បើផ្ទះរបស់គេត្រូវកំទេចចោល ដើម្បីកុំឲ្យប្រជាពលរដ្ឋដែលមានកូនក្មេង មនុស្សចាស់កើតមានជម្ងឺ ឬអាចដល់ស្លាប់ ដោយសារការរស់នៅកណ្តាលវាល ត្រូវខ្យល់កំដៅថ្ងៃ និងគ្មានស្បៀងអាហារ ។ ពីមុនមក គេតែងតែឃើញប្រជាពលរដ្ឋត្រូវទទួលរងគ្រោះ ដោយគ្រោះធម្មជាតិ ដូចជាខ្យល់ព្យុះ ទឹកលិច បានបាត់បង់ផ្ទះសំបែងទ្រព្យសម្បត្តិ ឥឡូវនេះយើងឃើញច្បាស់ហើយ គ្រោះធម្មជាតិនោះគឺអាជ្ញាធរខ្មែរនេះ

ឯង សម្លាប់ប្រជាពលរដ្ឋខ្លួនឯង ។ តាមធម្មតា គ្រប់រដ្ឋាភិបាលដែលមានប្រជាធិបតេយ្យ វៀរលែងតែរបបកុម្មុយនិស្តនិងរបបផ្តាច់ការ មុននឹងអនុវត្តផែនការណាមួយ គេតែងតែពិនិត្យមើលជាមុន តើផែនការនោះប៉ះពាល់ដល់សុខភាព ឬជីវិតរបស់ប្រជាពលរដ្ឋឬទេ ? បើមានការប៉ះពាល់ គេពុំអនុវត្តផែនការនោះទេ ។ បើគេអនុវត្ត គេត្រូវតែដោះស្រាយឲ្យជីវិតប្រជាពលរដ្ឋចេញផុតពីគ្រោះថ្នាក់ ព្រោះក្នុងរដ្ឋធម្មនុញ្ញរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ ត្រង់មាត្រា៣៩ ជំពូក៣ ចែងថា «ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ» ។ គេពុំបានដឹងច្បាស់ថា តើអាជ្ញាធរក្រុង យកប៉ូលិសទៅកំទេចផ្ទះនិងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនោះ ធ្វើលើសខ្លឹមសារនៃសាលក្រមនោះទេ ។ បើយោលតាមសំដីរបស់អាជ្ញាធរក្រុង បានសំដែងការសោកស្តាយ ចុះបើដឹងថា ការប្រព្រឹត្តនេះជាអំពើខុស ប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋ ហេតុដូចម្តេចបានជានៅតែប្រព្រឹត្ត ហើយមកសោកស្តាយជាក្រោយ ឬក៏ការប្រព្រឹត្តនោះលើសពីអត្ថន័យខ្លឹមសារនៃសាលក្រមនោះ ។ ការពិត ការសំដែងការសោកស្តាយនេះ គ្រាន់តែជារនាំងបិទបាំងចំពោះការរិះគន់ដ៏ខ្លាំងក្លារបស់សាធារណជន ដែលបានថ្កោលទោសចំពោះអាជ្ញាធរក្រុង ដែលបានប្រព្រឹត្តអំពើអមនុស្សធម៌នេះប៉ុណ្ណោះ ។ បើតាមច្បាប់ អាជ្ញាធរក្រុងពុំអាចរួចខ្លួនទេ ត្រូវតែសងការខូចខាតផ្ទះសំបែងទ្រព្យសម្បត្តិប្រជាពលរដ្ឋ ហើយបើធ្វើឲ្យប្រជាពលរដ្ឋមានជម្ងឺនិងរបួសស្នាមទៀត អាជ្ញាធរក្រុងត្រូវតែទទួលខុសត្រូវចំពោះមុខតុលាការថែមទៀត ។ អាជ្ញាធរក្រុងតោងតែដឹងថា ទឹកដីកម្ពុជាពុំមែនជាកម្មសិទ្ធិដាច់មុខរបស់ជនណាទេ ហើយក៏ពុំអាចជនណានៅពីលើច្បាប់ដែរ ។ ឥឡូវនេះប្រជាពលរដ្ឋគ្មានផ្ទះសំបែងដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅមុខ ចាត់ជាភាពអាសន្ន ដែលរដ្ឋត្រូវតែដោះស្រាយជាបន្ទាន់ ស្របតាមមាត្រា៣៦ ជំពូក៣នៃរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ននេះចែងថា «ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិទទួលរ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់» ។ សាលាក្រុងភ្នំពេញត្រូវតែសិក្សា មើលប្រទេសជឿនលឿន ដែលគេបានអនុវត្តមកហើយ ឧទាហរណ៍នៅស្រុកត្រជាក់ខ្លាំង ដែលចាំបាច់ត្រូវប្រើភ្លើងកំដៅ បើជនណាមិនបានបង់តម្លៃភ្លើងតាមការសន្យាពីរបីខែ គេត្រូវកាត់ឈប់ឲ្យប្រើ ប៉ុន្តែបើសង្កេតឃើញថា ជននោះគ្នាក្របានជាគ្មានប្រាក់បង់ គេក៏ពុំហ៊ានកាត់ដែរ ព្រោះនាំឲ្យប៉ះពាល់សុខភាពប្រជាពលរដ្ឋ ។ ដូចគ្នានេះ តើអាជ្ញាធរក្រុងបានគិតទេថា បើឲ្យត្រាក់ទ័រទៅឈូសបំផ្លាញផ្ទះនិងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋបែបនេះ តើអាចចាត់ថា បានសម្លាប់ប្រជាពលរដ្ឋដោយចេតនាយ៉ាងពិតប្រាកដឬទេ ? ដូច្នេះទាំងអ្នកចេញសាលក្រម ទាំងអ្នកអនុវត្តសាលក្រមគឺសាលាក្រុង ត្រូវឡើងតុលាការដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋស្លូតត្រង់ដែលទទួលរងគ្រោះនេះ ។៚